ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ.១០៥.អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# លទ្ធកម្មសាធារណៈ

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈត្រូវបានរៀបចំឡើងដោយធ្វើការកែលំអបំពេញបន្ថែមលើ អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ហើយត្រូវដាក់ឱ្យអនុវត្តជំនួសអនុក្រឹត្យលេខ ៦០ នេះ។

អនុក្រឹត្យនេះ ដាក់ចេញនូវ វិធាន និងបទប្បញ្ញត្តិ ដែលត្រូវអនុវត្តចំពោះគ្រប់កិច្ចលទ្ធកម្មសាធារណៈទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតអំពីប្រភពមូលនិធិ ក្នុងគោលដៅធានាឱ្យដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយ តម្លាភាព សមភាព ការប្រកួតប្រជែងពេញលេញ និងភាពតែមួយនៃនីតិវិធីលទ្ធកម្ម ព្រមទាំងធានាឱ្យសំរេចបាននូវការសន្សំសំចៃ គណនេយ្យភាព និងប្រសិទ្ធភាព ក្នុងដំណើរការលទ្ធកម្មទាក់ទងនឹង ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា។

ការអនុវត្តន៍លំអិតអំពីខ្លឹមសារនៃអនុក្រឹត្យនេះ នឹងកំណត់ដោយវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ព្រមទាំងសេចក្តីណែនាំទាំងឡាយ ឬបទប្បញ្ញត្តិដទៃទៀតជាធរមាន ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មិនមានវិសាលភាពគ្របដណ្តប់លើ កិច្ចសន្យាសម្បទានឡើយ។ វិធាន និងបទប្បញ្ញត្តិ ទាក់ទងនឹងកិច្ចសន្យាសម្បទាន ត្រូវស្ថិតនៅក្រោមច្បាប់ដោយឡែក។

ចំពោះកាតព្វកិច្ចរបស់រដ្ឋដែលមានចែងក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលព្រះរាជាណាចក្រកម្ពុជា ជាភាគី ឬក្នុងកិច្ចព្រមព្រៀងជាអន្តររដ្ឋាភិបាលរវាងព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដំណើរការនៃកិច្ចលទ្ធកម្មត្រូវអនុវត្តតាមការកំណត់នៃសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងនោះ។ ប្រសិនបើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងខាងលើ មិនបានចែងអំពីនីតិវិធីនៃលទ្ធកម្មណាមួយទេ ដំណើរការនៃលទ្ធកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

នៅក្នុងគ្រប់ដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈ ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាល រួមទាំង ឃុំ-សង្កាត់ ដែលចាប់ពីពេលនេះតទៅហៅថា "ស្ថាប័នអនុវត្តលទ្ធកម្ម-សល" ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមអនុក្រឹត្យនេះ ព្រមទាំង វិធាន និងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ "អវបលស" ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក៏ត្រូវអនុវត្តទៅលើឯកត្តបុគ្គល ឬក្រុមហ៊ុនឯកជនដែលធ្វើលទ្ធកម្ម ដោយប្រើប្រាស់មូលនិធិសាធារណៈផងដែរ ។

# ជំពូក ២

## វិធីសាស្ត្រ និងនីតិវិធីនៃលទ្ធកម្ម ទំនិញ សំណង់ និងសេវាកម្ម

## ផ្នែកទី ១

## វិធីសាស្ត្រនៃលទ្ធកម្ម

**មាត្រា ៤.-**

កិច្ចលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ត្រូវអនុវត្តតាមវិធីសាស្ត្រ ដូចខាងក្រោម :

១-ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ": វិធីសាស្ត្រនេះ ត្រូវប្រើសំរាប់គម្រោងចំណាយមានតម្លៃធំដែលនឹងកំណត់ក្នុង អវបលស ហើយមានការចូលរួមរបស់អ្នកដេញថ្លៃពីបរទេស និងអាចផ្តល់លក្ខណៈបច្ចេកទេសក្នុងកំរិតទូលំទូលាយ ដើម្បីធ្វើការជ្រើសរើសយកសំណើដេញថ្លៃ ដែលមានលក្ខណៈសន្សំសំចៃ និងផ្តល់អត្ថប្រយោជន៍ជាងគេ ។

២-ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស": វិធីសាស្ត្រនេះ ត្រូវអនុវត្ត ក្នុងករណីដែលមានផលិតកម្មក្នុងស្រុកគ្រប់គ្រាន់ ឬសមត្ថភាពសាងសង់គ្រប់គ្រាន់ ហើយទំហំទឹកប្រាក់នៃគម្រោងចំណាយមិនមានទំហំធំ ក្នុងការទាក់ទាញ ឬចាប់អារម្មណ៍ពីអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការបរទេស ដើម្បីធ្វើការជ្រើសរើសយកសំណើដេញថ្លៃ ដែលមានលក្ខណៈសន្សំសំចៃ និងផ្តល់អត្ថប្រយោជន៍ជាងគេ ។

៣-ការពិគ្រោះថ្លៃ "ពថ" : វិធីសាស្ត្រនេះ ត្រូវប្រើសំរាប់កិច្ចលទ្ធកម្មលើ ទំនិញ សំណង់ និងសេវាកម្ម ដែលមានជាស្រេចនៅលើទីផ្សារក្នុងស្រុក ។ ការពិគ្រោះថ្លៃ អាចពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់ក្នុងស្រុក ឬក្រៅស្រុក ។

៤-ការស្ទង់តម្លៃ "សត" : វិធីសាស្ត្រនេះ ត្រូវយកទៅប្រើសំរាប់លទ្ធកម្មលើមុខទំនិញតូចតាច ហើយមានតម្លៃតិចតួច ។

**មាត្រា ៥.-**

កំរិតទឹកប្រាក់ជាមូលដ្ឋានសំរាប់កំណត់ជ្រើសរើសវិធីសាស្ត្រនៃលទ្ធកម្មណាមួយ ដូចមានចែងក្នុងមាត្រា ៤ ខាងលើនេះ នឹងកំណត់ក្នុង អវបលស ។ កំរិតទឹកប្រាក់ទាំងនេះ មិនមែនជាតម្លៃថេរ ហើយអាចត្រូវកែប្រែបានដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ស្ថាប័នអនុវត្តលទ្ធកម្ម មិនត្រូវបំបែកគម្រោងចំណាយលទ្ធកម្មរបស់ខ្លួន ជាកិច្ចសន្យាដោយឡែកៗ ក្នុងគោលបំណងបំពានវិធីសាស្ត្រ ដូចបានកំណត់ក្នុងមាត្រា ៤ ខាងលើ នៃអនុក្រឹត្យនេះឡើយ ។

**មាត្រា ៦.-**

កិច្ចលទ្ធកម្មក៏អាចធ្វើតាមវិធីសាស្ត្រលទ្ធកម្មដោយឡែក ដែលរួមមាន:

១-ការចុះកិច្ចសន្យាផ្ទាល់ "កផ" : វិធីសាស្ត្រនេះ អាចត្រូវបានប្រើក្នុងករណីពិសេស ដូចខាងក្រោម:

-ឧបករណ៍ដែលត្រូវការមានប្រភពតែមួយគត់

-ករណីចាំបាច់សំរាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង ហើយតម្រូវការចាំបាច់បន្ទាន់រយៈពេលខ្លី មិនអាចរង់ចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន

-សំរាប់គោលបំណងសិក្សាស្រាវជ្រាវដកបទពិសោធន៍ ឬអភិវឌ្ឍន៍

២-ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម "កអជ" : ត្រូវបានប្រើសំរាប់ស្ថាប័នអនុវត្តលទ្ធកម្មណាដែលមានស្រាប់នូវ បច្ចេកទេសជំនាញ កំលាំងពលកម្ម និងឧបករណ៍ សំរាប់បំពេញការងារក្នុងគម្រោងនោះ ។ វិធីសាស្ត្រនេះ អាចអនុវត្តនៅក្នុងករណី ដូចខាងក្រោម :

-បរិមាណការងារមិនអាចកំណត់បានជាមុន

-ការងារមានទំហំតូច ទីកន្លែងមិនអំណោយផល ស្ថិតនៅទីតាំងបែកខ្ញែកច្រើន ដែលបណ្តាក្រុមហ៊ុនសំណង់មិននិយមចូលចិត្តចូលរួមដេញថ្លៃ

-ការងារដែលត្រូវធ្វើបន្ថែម ដើម្បីចៀសវាងការខកខានដល់ការងារដែលកំពុងដំណើរការ

-ហានិភ័យនៃការពន្យារពេលដែលកើតឡើងជាបន្ទុករបស់រដ្ឋាភិបាលជាជាងបន្ទុករបស់អ្នកទទួលការងគជន

-មានគ្រោះមហន្តរាយធម្មជាតិ ឬតម្រូវការបន្ទាន់ ដែលត្រូវយកចិត្តទុកដាក់

៣-លទ្ធកម្មភាគកម្មសហគមន៍ "លភស": វិធីសាស្ត្រនេះ ត្រូវប្រើដើម្បីឱ្យសម្រេចបាននូវគោលបំណងរបស់សង្គមជាក់លាក់ នៅពេលណាមានការជ្រើសរើសសមាសភាពនៃគម្រោង ចំពោះ :

- ការអំពាវនាវឱ្យមានការចូលរួមពីសហគមន៍ក្នុងស្រុក ឬពីអង្គការក្រៅរដ្ឋាភិបាល ក្នុងការផ្តល់សេវាកម្ម

- បង្កើនការប្រើប្រាស់ចំណេះដឹង និងសំភារៈក្នុងស្រុក

- ការប្រមូលផ្តុំប្រើប្រាស់ពលកម្ម និងសំភារៈបច្ចេកទេសសមស្របជាមួយសេដ្ឋកិច្ចក្នុងស្រុក

ការអនុវត្តនីតិវិធីសាស្ត្រលទ្ធកម្មដោយឡែកពីខាងលើនេះ ត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិធីសាស្ត្រលទ្ធកម្មដោយឡែក មិនមានកំរិតកំណត់ទឹកប្រាក់ឡើយ ។

## ផ្នែកទី ២

## នីតិវិធីនៃលទ្ធកម្ម

**មាត្រា ៧.-**

រាល់កិច្ចលទ្ធកម្មត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ដើម្បីធានាឱ្យកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយ តម្លាភាព ភាពយុត្តិធម៌ សមធម៌ និងការប្រកួតប្រជែងពេញលេញ ។

នីតិវិធីលំអិតទាំងអស់ នឹងត្រូវកំណត់ក្នុង អវបលស ។

**មាត្រា ៨.-**

នីតិវិធីជាមូលដ្ឋានសំរាប់អនុវត្តវិធីសាស្ត្រ ដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ដែលការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" ពិគ្រោះថ្លៃ "ពថ" និងស្ទង់តម្លៃ "សត" មានដូចខាងក្រោម :

១-ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ" : ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈទាំងក្នុងប្រទេស និងក្រៅប្រទេស ហើយត្រូវបើកចំហសំរាប់អ្នកដេញថ្លៃទាំងអស់។ ឯកសារដេញថ្លៃ ត្រូវរៀបចំឱ្យបានគ្រប់គ្រាន់សំរាប់លក់ឱ្យអ្នកដេញថ្លៃដែលចង់ទិញទាំងអស់ ដោយស្មើភាព។ រាល់ការបើកឯកសារដេញថ្លៃ ត្រូវធ្វើឡើងជាសាធារណៈ។ ការផ្សព្វផ្សាយសំរាប់ "ដបអ" ត្រូវមានរយៈពេលសមស្រប ដែលនឹងត្រូវកំណត់ដោយ អវបលស ។

២-ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" : គ្រាន់តែធ្វើការផ្សព្វផ្សាយនៅក្នុងស្រុក ប៉ុន្តែត្រូវបើកចំហសំរាប់អ្នកដេញថ្លៃទាំងអស់។ ឯកសារដេញថ្លៃត្រូវរៀបចំឱ្យបានគ្រប់គ្រាន់ សំរាប់លក់ឱ្យអ្នកដេញថ្លៃ រួមទាំងអ្នកដេញថ្លៃអន្តរជាតិដែលចង់ទិញឯកសារ ដោយស្មើភាពគ្នា ។ រាល់ការបើកឯកសារដេញថ្លៃ ត្រូវធ្វើឡើងជាសាធារណៈ។ ការផ្សព្វផ្សាយសំរាប់ "ដបស" ត្រូវមានរយៈពេលសមស្រប ដែលនឹងត្រូវកំណត់ដោយ អវបលស។

៣-ការពិគ្រោះថ្លៃ "ពថ" : ត្រូវអញ្ជើញអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការឱ្យដាក់តារាងតម្លៃដែលបិទជិត ហើយការបើកសំណើពិគ្រោះថ្លៃនឹងត្រូវធ្វើឡើងជាសាធារណៈ ។ លិខិតអញ្ជើញ ត្រូវបានផ្ញើឱ្យអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការចំនួនមិនតិចជាងបី ហើយត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត និងត្រូវបើកចំហសំរាប់អ្នកដេញថ្លៃទាំងអស់ដែលចង់ចូលរួម ។

៤-ការស្ទង់តម្លៃ "សត" : ត្រូវទទួល និងធ្វើការកត់ត្រាយ៉ាងតិចបំផុតចំនួនបីនាក់ តាមរយៈការសួរតាមទូរស័ព្ទ និងការសួរផ្ទាល់មាត់ពីក្រុមហ៊ុន ឬពីប្រភពណាមួយ ដោយធ្វើកំណត់ហេតុ និងត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ឬបុគ្គលដែលផ្តល់វិក័យប័ត្រជាទម្រង់ ឬបញ្ជីប៉ាន់តម្លៃទាបសមស្របជាងគេបំផុត ។

មាត្រា ៩.-

ការប្រើប្រាស់គំរូឯកសារដេញថ្លៃរបស់ជាតិ គឺជាការចាំបាច់បំផុត លើកលែងតែឯកសារលទ្ធកម្មឯកទេសជំនាញ ដូចជា ផ្នែកឱសថ វត្ថុធាតុដើមតាមការបញ្ជាទិញ ប្រព័ន្ធព័ត៌មានស្មុគស្មាញ ការងារបច្ចេកទេសស្មុគស្មាញ ។

នៅពេលស្ថាប័នអនុវត្តលទ្ធកម្មកំណត់អត្តសញ្ញាណគំរូឯកសារដេញថ្លៃរបស់អន្តរជាតិសមស្រប ដោយធ្វើការកែសំរួល ដើម្បីឆ្លុះបញ្ចាំងតម្រូវការរបស់ខ្លួនហើយ ឯកសារបែបនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញ និងត្រូវមានការអនុមត័យល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលលក់ ឬប្រគល់ឯកសារឱ្យអ្នកដេញថ្លៃ ។ ឯកសារនេះនឹងក្លាយជា ឯកសារគំរូរបស់ជាតិសំរាប់អនុវត្តលទ្ធកម្មឯកទេសជំនាញ។

មាត្រា ១០.-

ការកំណត់បុរេលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការដែលមានសក្តានុពល ត្រូវធ្វើឡើងចំពោះតែកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ធំ ហើយមានភាពស្មុគស្មាញប៉ុណ្ណោះ ដូចជា ការផ្គត់ផ្គង់បរិក្ខារតាមបញ្ជាអ្នកទិញ សំណង់រោងចក្រឧស្សាហកម្ម សេវាកម្មពិសេស បច្ចេកវិទ្យា និងព័ត៌មានវិទ្យាស្មុគស្មាញ និងគ្រឿងសង្ហារិមមានលក្ខណៈស្មុគស្មាញ។ នីតិវិធីពាក់ព័ន្ធការធ្វើបុរេលក្ខណៈសម្បត្តិ នឹងកំណត់ក្នុង អវបលស។

### មាត្រា ១១.-

ការបើកឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ" ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" ការពិគ្រោះថ្លៃ "ពថ" នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែទទួលបានឯកសារដេញថ្លៃតិចបំផុតចំនួនបី ។ ប្រសិនបើលទ្ធផលទទួលឯកសារដេញថ្លៃមានចំនួនតិចជាងបី ឯកសារដេញថ្លៃមិនត្រូវបើក ហើយត្រូវបញ្ជូនឯកសារទាំងនោះ ត្រឡប់ទៅកាន់អ្នកដេញថ្លៃវិញ បន្ទាប់មកត្រូវធ្វើការពិនិត្យកែលំអឯកសារដេញថ្លៃឡើងវិញ ដើម្បីបង្កើនកំរិតនៃការប្រកួតប្រជែងជាសាធារណៈជាលើកទីពីរ ។

ឯកសារដេញថ្លៃ ត្រូវប្រគល់ជូនដោយមិនគិតថ្លៃ ទៅឱ្យអ្នកដេញថ្លៃណាដែលបានដាក់ពាក្យដេញថ្លៃលើកមុន និងត្រូវលក់ទៅឱ្យអ្នកដេញថ្លៃផ្សេងទៀតដែលបានស្នើសុំ។ ក្រោយការផ្សព្វផ្សាយជាសាធារណៈលើកទីពីរ ទោះបីលទ្ធផលទទួលបានឯកសារដេញថ្លៃចំនួនប៉ុន្មាន ក៏ត្រូវតែធ្វើការបើកឯកសារទាំងនោះជាសាធារណៈ និងធ្វើការវាយតម្លៃដែរ។

ក្នុងករណី គ្មានអ្នកចូលរួមដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំរបាយការណ៍បញ្ជាក់ពីមូលហេតុដែលគ្មានអ្នកចូលរួមដេញថ្លៃ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសំរេច។

### មាត្រា ១២.-

ការបើកឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ" ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" ការពិគ្រោះថ្លៃ "ពថ" ត្រូវធ្វើឡើងភ្លាម១ ក្រោយកាលបរិច្ឆេទបញ្ចប់ការទទួលឯកសារដេញថ្លៃ និងត្រូវធ្វើឡើងជាសាធារណៈ ។

ការបើកឯកសារដេញថ្លៃត្រូវធ្វើកំណត់ហេតុ និងត្រូវផ្តល់កំណត់ហេតុនោះ ឱ្យក្រុមហ៊ុនទាំងអស់ដែលបានដាក់សំណើសុំដេញថ្លៃ ហើយកំណត់ហេតុនេះ ក៏អាចផ្តល់ឱ្យគ្រប់ភាគីដែលស្នើសុំផងដែរ។ កំណត់ហេតុបើកឯកសារដេញថ្លៃត្រូវតែកត់ត្រាយ៉ាងហោចណាស់ ឈ្មោះ និងសញ្ជាតិអ្នកដេញថ្លៃ តម្លៃដាក់ដេញថ្លៃ សុពលភាពឯកសារដេញថ្លៃ វត្តមានអ្នកចូលរួម ចំនួនប្រាក់កក់ដេញថ្លៃ និងសុពលភាពប្រាក់កក់ធានាការដេញថ្លៃ ។

## ជំពូក ៣

## លទ្ធកម្មសេវាទីប្រឹក្សា

### មាត្រា ១៣.-

ទីប្រឹក្សាអាចជ្រើសរើសយកមកដើម្បីផ្តល់នូវសេវាឯកទេសក្នុងការអនុវត្តន៍គម្រោង ឬកិច្ចសន្យាសំខាន់១ ឬមួយផ្តល់ជំនួយ ឬយោបល់ជំនាញ ក្នុងការងារពង្រឹងស្ថាប័ន ឬសមត្ថភាព។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សា ឬជាឯកត្តជន។

### មាត្រា ១៤.-

នីតិវិធីក្នុងការជ្រើសរើស និងការវាយតម្លៃក្រុមហ៊ុនទីប្រឹក្សា នឹងកំណត់ក្នុង អវបលស ហើយនីតិវិធីទាំងនេះចាំបាច់ត្រូវអនុវត្តសំរាប់គ្រប់ករណី។ គំរូឯកសារដេញថ្លៃ និងទម្រង់កិច្ចសន្យានឹងត្រូវកំណត់ក្នុងឧបសម្ព័ន្ធនៃ អវបលស ។ ឯកសារគំរូទាំងអស់នេះ ត្រូវប្រើប្រាស់នៅក្នុងគ្រប់ករណីទាំងអស់ ។

មាត្រា ១៥.-

ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យក្រុមហ៊ុនទីប្រឹក្សានានា ចូលរួមដាក់ចំណាប់អារម្មណ៍ និងបញ្ជាក់ពីចំណាប់អារម្មណ៍ក្នុងការបំពេញការងារ ។ ក្នុងករណីតម្លៃប៉ាន់ស្មាននៃសេវាទីប្រឹក្សាខ្ពស់ជាងកម្រិតទឹកប្រាក់ដែលបានកំណត់ក្នុង អវបលស ការផ្សព្វផ្សាយជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ត្រូវធ្វើឡើងជាភាសាខ្មែរ និងភាសាអន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារនោះ ។

មាត្រា ១៦.-

ការជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់ឯកត្តជនទាក់ទងនឹងទីកន្លែងការងារដែលធ្លាប់បានបំពេញ ។ ការអញ្ជើញឱ្យដាក់ចំណាប់អារម្មណ៍ ត្រូវផ្សព្វផ្សាយជាសាធារណៈទូទាំងប្រទេស ហើយនៅពេលតម្លៃប៉ាន់ស្មាននៃការងារត្រូវបំពេញលើសពីកម្រិតទឹកប្រាក់ដែលបានកំណត់ក្នុង អវបលស នោះ ការផ្សព្វផ្សាយជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងជាភាសាខ្មែរ និងភាសាអន្តរជាតិ ផ្អែកតាមទំហំការងារត្រូវបំពេញ ។

ទីប្រឹក្សាឯកត្តជន នឹងត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងលិខិតអញ្ជើញដាក់ចំណាប់អារម្មណ៍ និងការអញ្ជើញឱ្យចូលរួមធ្វើការចរចា ដើម្បីចុះកិច្ចសន្យាជាមួយស្ថាប័នអនុវត្តលទ្ធកម្ម ។

## ជំពូក ៤

## ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

មាត្រា ១៧.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា "ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ" ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់កម្រិតទឹកប្រាក់សំរាប់អនុវត្តវិធីសាស្ត្រនៃលទ្ធកម្ម រៀបចំគោលនយោបាយនៃលទ្ធកម្ម និងនីតិវិធីលំអិតនៃលទ្ធកម្ម សំរាប់អនុវត្តស្របទៅតាមបទប្បញ្ញត្តិដែលមានស្រាប់ និងអនុវត្តអំណាចដទៃទៀតតាមការចាំបាច់ ដើម្បីធានាអោយមុខងារ និងការអនុវត្តន៍ដំណើរការបានល្អ ។

មាត្រា ១៨.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចធ្វើការកែលំអ និងបំពេញបន្ថែមលើវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ "អវបលស" ។ រាល់ការកែលំអ ឬការបំពេញបន្ថែមនេះ ត្រូវធ្វើឡើងដោយប្រកាស ឬសារាចរណែនាំ ។

មាត្រា ១៩.-

ស្របតាមអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកដ្ឋានលទ្ធកម្មសាធារណៈ ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងលទ្ធកម្មសាធារណៈនៅតាមបណ្តា ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ឃុំ សង្កាត់ សម្រាប់គ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាលទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពទុន

# ជំពូក ៥

## ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម

### មាត្រា ២០.-

ការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុក្រឹត្យនេះ ក៏ដូចជា អវបលស ជាបន្ទុករបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំរាល់កិច្ចលទ្ធកម្មរបស់ស្ថាប័នខ្លួន ។

### មាត្រា ២១.-

ស្ថាប័នអនុវត្តលទ្ធកម្មនីមួយៗ ត្រូវបង្កើតអង្គភាពលទ្ធកម្ម "អល" ដែលមានថ្នាក់ស្មើការិយាល័យ ដើម្បីសំរួលការអនុវត្តន៍កិច្ចលទ្ធកម្មឱ្យបានពេញលេញ និងទទួលរ៉ាប់រងលើរាល់កិច្ចលទ្ធកម្មទាំងអស់ នៅក្នុងស្ថាប័នរបស់ខ្លួន។ តួនាទីលំអិត ការទទួលខុសត្រូវ និងការតែងតាំង ឬផ្លាស់ប្តូរប្រធានអង្គភាពលទ្ធកម្ម នឹងកំណត់ក្នុង អវបលស។ ប្រធានអង្គភាពលទ្ធកម្ម និងសមាជិករបស់ខ្លួន មិនត្រូវកាន់មុខងារផ្សេងទៀតនៅក្នុងស្ថាប័ន ឬក្រសួង ហើយត្រូវបំរើការងារពេញម៉ោងសំរាប់អង្គភាពលទ្ធកម្ម ។

### មាត្រា ២២.-

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងអនុម័ត នៅដើមឆ្នាំសារពើពន្ធនីមួយៗ ។ រាល់គម្រោងចំណាយដែលត្រូវអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈ ត្រូវកត់បញ្ចូលក្នុងផែនការលទ្ធកម្ម។ ការរៀបចំផែនការលទ្ធកម្ម ត្រូវផ្អែកតាមទម្រង់ដែលនឹងកំណត់ក្នុង អវបលស។ ក្នុងករណីចាំបាច់ ផែនការលទ្ធកម្មអាចកែតម្រូវនៅឆមាសទី ២ នៃឆ្នាំសារពើពន្ធនីមួយៗ។ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុវត្តកិច្ចលទ្ធកម្មឱ្យបានទៀងទាត់តាមកម្មវិធី ដែលបានកំណត់ក្នុងផែនការលទ្ធកម្ម។

### មាត្រា ២៣.-

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីទិន្នន័យនៃកិច្ចសន្យាទាំងអស់ រួមទាំងការងារវិសហមជ្ឈការលទ្ធកម្ម តាមគំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ឱ្យ ។ ក្នុងករណីអាក់ខានមិនបានបញ្ជូនទិន្នន័យគ្រប់គ្រាន់ទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមានវិធានការដាក់វិន័យតាមការជាក់ស្តែង ។

ស្ថាប័នអនុវត្តលទ្ធកម្មទាំងអស់ដែលប្រើមូលនិធិសាធារណៈ ត្រូវរក្សាទុករបាយការណ៍លទ្ធកម្មដែលនឹងកំណត់ក្នុង អវបលស ហើយរបាយការណ៍ទាំងនោះត្រូវផ្តល់ និងអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យដោយមិនមានការលាក់បាំងនៅពេលអាជ្ញាធរមានសមត្ថកិច្ចចាំបាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ឬធ្វើការស៊ើបអង្កេតលើបណ្តឹងតវ៉ាណាមួយ និងត្រូវផ្តល់ការអនុញ្ញាតឱ្យពិនិត្យកំណត់ហេតុដទៃទៀតពាក់ព័ន្ធនឹងដំណើរការកិច្ចលទ្ធកម្ម នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចស្នើសុំ។

# ជំពូក ៦

## គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា "គបវប"

### មាត្រា ២៤.-

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា "គបវប" មួយ ដែលទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្ម ឯកសារដេញថ្លៃ ការផ្តល់អនុសាសន៍ដើម្បីប្រគល់កិច្ចសន្យា ការអនុវត្តន៍កិច្ចសន្យា និងផ្តល់អនុសាសន៍លើបណ្តឹងតវ៉ា។ ការរៀបចំបង្កើតគណៈកម្មការលទ្ធកម្មសំរាប់ ឃុំ-សង្កាត់ នឹងកំណត់ដោយឡែកក្នុង អវបលស។

### មាត្រា ២៥.-

សមាជិក គបវប ដែលត្រូវតែងតាំងដោយប្រធានស្ថាប័ន មានអាណត្តិការងាររយៈពេល ២ ឆ្នាំ ។ អាណត្តិនេះអាចបន្តបានរយៈពេល ១ ឆ្នាំ ទៀត ប៉ុន្តែមិនឱ្យលើសរយៈពេលសរុប ៣ ឆ្នាំឡើយ។ សមាជិក គបវប ដែលបានបំរើការងាររយៈពេល ៣ ឆ្នាំហើយនោះ អាចត្រូវតែងតាំងឡើងវិញបាន ក្រោយពីរយៈពេលយ៉ាងតិចបំផុត ១ ឆ្នាំបន្ទាប់ពីបានបញ្ចប់ រយៈពេល ៣ ឆ្នាំ ជា សមាជិករបស់ គបវប ។

សមាជិក គបវប ដែលត្រូវតែងតាំងដោយប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវមានចំនួនពី ៤ ទៅ ៦ នាក់ បន្ថែមលើប្រធាន និងអនុប្រធាន គបវប ដែលបានចាត់តាំងស្របតាមមាត្រា ២៦ នៃអនុក្រឹត្យនេះ ដែលក្នុងនោះត្រូវមានយ៉ាងហោចណាស់ សមាជិកម្នាក់មានជំនាញហិរញ្ញវត្ថុ និងសមាជិកម្នាក់ទៀត មានជំនាញបច្ចេកទេស ដូចជា វិស្វករជាដើម។ ប្រធានស្ថាបនអនុវត្តលទ្ធកម្ម អាចចាត់តាំងសមាជិកបណ្តោះអាសន្ន សំរាប់អនុវត្តលទ្ធកម្មពិសេសណាមួយដែលត្រូវការចាំបាច់នូវជំនាញ និងចំណេះដឹងពិសេស។ សមាជិកបណ្តោះអាសន្ន ត្រូវរំសាយដោយស្វ័យប្រវត្តិក្រោយកិច្ចលទ្ធកម្មពិសេសបានបញ្ចប់ ។

នាយកដ្ឋានលទ្ធកម្មសាធារណៈ នឹងត្រូវបានស្ថាប័នអនុវត្តលទ្ធកម្មអញ្ជើញឱ្យចូលរួម និងមានសិទ្ធិចូលរួមគ្រប់ការពិភាក្សារបស់ គបវប ជាអ្នកសង្កេតការណ៍។ តួនាទី និងភារកិច្ច របស់អ្នកសង្កេតការណ៍ នឹងកំណត់ក្នុង អវបលស ។

### មាត្រា ២៦.-

គបវប ត្រូវមានសមាជិកជាអចិន្ត្រៃយ៍ ។ ប្រធានអង្គភាពលទ្ធកម្ម "អល" ត្រូវធ្វើជាលេខាធិការរបស់ គបវប ។ សិទ្ធិដឹកនាំរបស់ គបវប ត្រូវមានប្រធានមួយរូប អនុប្រធានទី ១ មួយរូប និងអនុប្រធានទី ២ មួយរូប ។ សិទ្ធិដឹកនាំរបស់ គបវប ត្រូវប្រែប្រួលតាមកំរិតនៃតម្លៃកិច្ចលទ្ធកម្មដែលនឹងកំណត់ក្នុង អវបលស។ សិទ្ធិដឹកនាំ គបវប ត្រូវបានកំណត់តាមកំរិត ដូចខាងក្រោម :

- លទ្ធកម្មកំរិតខ្ពស់ : ដឹកនាំដោយប្រធាន គបវប ជាប្រធានស្ថាប័ន
- លទ្ធកម្មកំរិតមធ្យម : ដឹកនាំដោយអនុប្រធានទី ១ គបវប
- លទ្ធកម្មកំរិតទាប : ដឹកនាំដោយអនុប្រធានទី ២ គបវប

អនុប្រធានទី ១ និងអនុប្រធានទី ២ គបវប ត្រូវបានតែងតាំងដោយប្រធានស្ថាប័ន និងត្រូវបានប្រគល់សិទ្ធិពេញលេញឱ្យធ្វើជាផ្នែកមួយរបស់ គបវប ក្នុងការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃ និងចុះកិច្ចសន្យា ។

**មាត្រា ២៧.-**

គបវប មានភារកិច្ចត្រួតពិនិត្យលើសកម្មភាពលទ្ធកម្ម មានសិទ្ធិយល់ព្រមលើរបាយការណ៍វាយតម្លៃ និងរៀបចំចុះកិច្ចសន្យាតាមនីតិវិធី ទៅតាមកំរិតទឹកប្រាក់ដែលនឹងកំណត់ក្នុង អវបលស ។ គបវប ត្រូវធ្វើការសម្រេចដាច់ខាតចំពោះរបាយការណ៍វាយតម្លៃ និងការផ្តល់អនុសាសន៍ ដើម្បីប្រគល់កិច្ចសន្យា ។

អនុប្រធានទី ១ និងអនុប្រធានទី ២ គបវប ត្រូវបានផ្តល់សិទ្ធិដើម្បីចុះហត្ថលេខាក្នុងនាមស្ថាប័ន ដោយមិនចាំបាច់មានការយល់ព្រមពីប្រធានស្ថាប័នឡើយ ។ នៅពេលដែលថ្នាក់សម្រេចរបស់ គបវប តាមកំរិតនីមួយៗ បានអនុម័តយល់ព្រមលើកិច្ចលទ្ធកម្មហើយ នោះមិនតម្រូវឱ្យមានការយល់ព្រមបន្ថែមពីស្ថាប័នណាទៀតឡើយ លើកលែងតែចំពោះករណីដូចខាងក្រោម :

-កិច្ចសន្យាលើសកំរិតទឹកប្រាក់ ដែលនឹងកំណត់ក្នុង អវបលស ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសំរេច ។

-កិច្ចសន្យាលើសកំរិតទឹកប្រាក់ ដែលនឹងកំណត់ក្នុង អវបលស ហើយជាគម្រោងដែលមានលក្ខណៈប៉ះពាល់ស្រួចស្រាល់ដល់នយោបាយ ឬមានឥទ្ធិពលខ្លាំងដល់សង្គម ឬសីលធម៌ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសំរេច ។

## ជំពូក ៧

## តម្រូវការចាំបាច់សំរាប់កិច្ចលទ្ធកម្ម

**មាត្រា ២៨.-**

គ្រប់លទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សាទាំងអស់ ត្រូវតែធ្វើការផ្សព្វផ្សាយជាសាធារណៈ លើកលែងតែការស្ទង់តម្លៃ និងលទ្ធកម្មដែលអនុវត្តតាមវិធីសាស្ត្រដោយឡែក ដូចមានចែងនៅក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ។

អ្នកដេញថ្លៃទាំងអស់ មិនតម្រូវឱ្យធ្វើការចុះបញ្ជីធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់ក្រុមហ៊ុន ដើម្បីមានសិទ្ធិពេញលេញក្នុងការជាវឯកសារដេញថ្លៃ ឬសំណើសុំដាក់ដេញថ្លៃឡើយ លើកលែងតែអ្នកទទួលការសាងសង់លើគម្រោងចំណាយដែលប្រើប្រាស់ថវិកាជាតិ ត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា ២៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៩.-**

ដើម្បីមានសិទ្ធិចូលរួមនៅក្នុងគម្រោងការងារសាធារណៈ អ្នកទទួលការសាងសង់ត្រូវតែចុះឈ្មោះក្នុងបញ្ជីធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់ក្រុមហ៊ុន ដោយយោងលើប្រភេទគម្រោងដែលអ្នកទទួលការសាងសង់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញ ។ ការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់ក្រុមហ៊ុន នឹងត្រូវធ្វើឡើងដោយគណៈកម្មាធិការមួយ

ដែលមានតំណាងនាយកដ្ឋានលទ្ធកម្មសាធារណៈធ្វើជាប្រធាន តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតំណាងឧស្សាហកម្មសំណង់ក្នុងស្រុក ធ្វើជាសមាជិក និងត្រូវចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រុមបច្ចេកទេសមួយអាចត្រូវបានបង្កើតឡើងនៅរាល់ពេលធ្វើការវាយតម្លៃលើពាក្យស្នើសុំធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់ក្រុមហ៊ុន ។

ការណែនាំលំអិត សំរាប់ការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់ក្រុមហ៊ុន សំរាប់អ្នកទទួលការសាងសង់ នឹងកំណត់ក្នុង អវបលស និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៣០.-**

មានតែឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ" និងការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" ប៉ុណ្ណោះ ដែលនឹងត្រូវលក់ឱ្យអ្នកដេញថ្លៃ ។ ឯកសារលទ្ធកម្មផ្សេងទៀតត្រូវចែកជូនដោយមិនគិតថ្លៃ ។ តម្លៃលក់ឯកសារដេញថ្លៃ ត្រូវស្ថិតនៅក្រោមការណែនាំដែលនឹងកំណត់ក្នុង អវបលស ។

**មាត្រា ៣១.-**

គ្រប់ឯកសារដេញថ្លៃ ដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ "ដបអ" ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក "ដបស" និងឯកសារបុរេលក្ខណៈសម្បត្តិ ត្រូវរៀបចំឱ្យរួចស្រេចបាច់សំរាប់លក់ និងផ្តល់ឱ្យអ្នកចូលរួមដេញថ្លៃបានទាន់ពេលវេលា និងស្មើភាព ។ ការពន្យាររយៈពេលផ្សព្វផ្សាយ ត្រូវបានកំណត់ឡើងវិញចំពោះហេតុផលសមស្របណាមួយដែលបណ្តាលឱ្យយឺតយ៉ាវក្នុងការរៀបចំឯកសារដេញថ្លៃ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការពន្យារកាលបរិច្ឆេទសំរាប់ទទួលឯកសារដេញថ្លៃ ឬឯកសារបុរេលក្ខណៈសម្បត្តិ ដើម្បីទុកពេលគ្រប់គ្រាន់ឱ្យអ្នកដេញថ្លៃរៀបចំឯកសារបានទាន់ពេល ។

ពេលវេលាគ្រប់គ្រាន់នឹងកំណត់ក្នុង អវបលស ដើម្បីជួយឱ្យអ្នកដេញថ្លៃ និងទីប្រឹក្សាទាំងអស់ រៀបចំឯកសារ និងដាក់សំណើដេញថ្លៃ ។

**មាត្រា ៣២.-**

រាល់ការប្រាស្រ័យទាក់ទងជាមួយអ្នកដេញថ្លៃ នៅក្នុងអំឡុងពេលកំពុងដំណើរការដេញថ្លៃ ការវាយតម្លៃ និងការរៀបចំធ្វើកិច្ចសន្យា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយក្នុងករណីចរចាថ្លៃ ត្រូវមានកំណត់ហេតុនៃការចរចាថ្លៃដែលត្រូវចុះហត្ថលេខាដោយភាគីទាំងពីរ ។

**មាត្រា ៣៣.-**

គ្មានអ្នកដេញថ្លៃណាមួយត្រូវបានអនុញ្ញាតឱ្យដឹង ឬបានទទួលព័ត៌មានអំពីលទ្ធផលនៃការដេញថ្លៃជាផ្លូវការឡើយ ក្នុងខណៈដែលព័ត៌មាននេះ មិនទាន់បានប្រកាសជាសាធារណៈ ។

**មាត្រា ៣៤.-**

គ្រប់សំណើដេញថ្លៃ និងសំណើជ្រើសរើសទីប្រឹក្សាទាំងអស់ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ) ត្រូវតែ បើកជាសាធារណៈ ហើយកំណត់ហេតុត្រូវផ្តល់ឱ្យក្រុមហ៊ុន និងបុគ្គលដែលបានចូលរួមទាំងអស់ ...

ប្រកាសលើបញ្ជរព័ត៌មាននៅស្ថាប័នអនុវត្តលទ្ធកម្ម ដែលសាធារណជនទូទៅអាចមើលឃើញចាប់ពីក្រោយថ្ងៃបើកឯកសារដេញថ្លៃ ឬបើកសំណើសុំដេញថ្លៃ ឬបន្ទាប់ពីការប្រគល់កិច្ចសន្យាសំរាប់មួយរយៈពេលយ៉ាងខ្លី ដែលនឹងកំណត់ក្នុង អវបលស ។ កំណត់ហេតុថតចម្លង ក៏អាចផ្តល់ឱ្យសាធារណជនណាដែលបានដាក់ពាក្យស្នើសុំ ។

មាត្រា ៣៥.-

គ្មានកិច្ចសន្យាណាមួយនឹងត្រូវបានប្រគល់ជូនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលមិនបានបញ្ចូលនៅក្នុងឯកសារដេញថ្លៃ ទាំងច្បាប់ដើម ឬឯកសារកែប្រែក្នុងឯកសារដេញថ្លៃ និងសំណើឱ្យដាក់ដេញថ្លៃ ឬការអញ្ជើញឱ្យដាក់ចំណាប់អារម្មណ៍សំរាប់ទីប្រឹក្សាឯកត្តជន ។

មាត្រា ៣៦.-

របាយការណ៍វាយតម្លៃប្រគល់កិច្ចសន្យានីមួយៗ ត្រូវរក្សាទុកជាឯកសារនៅស្ថាប័នអនុវត្តលទ្ធកម្ម ។ របាយការណ៍វាយតម្លៃ ត្រូវតែគោរពតាមគំរូស្តង់ដារ ដែលនឹងកំណត់ក្នុង អវបលស។ សេចក្តីសង្ខេបអំពីលទ្ធផលនៃការវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវបិទប្រកាសលើបញ្ជរព័ត៌មាន ឬដាក់ក្នុងគេហទំព័រប្រសិនបើមាន នៅស្ថាប័នអនុវត្តលទ្ធកម្មដើម្បីឱ្យសាធារណជនទូទៅអាចមើលឃើញ ចាប់ពីក្រោយថ្ងៃបើកឯកសារដេញថ្លៃ ឬបើកសំណើសុំដេញថ្លៃ ឬបន្ទាប់ពីការប្រគល់កិច្ចសន្យា សំរាប់មួយរយៈពេលយ៉ាងខ្លី ដែលនឹងកំណត់ក្នុង អវបលស ហើយសេចក្តីសង្ខេបកំណត់ហេតុនោះ ក៏ត្រូវផ្តល់ឱ្យផងដែរ ចំពោះក្រុមហ៊ុន និងបុគ្គល ដែលបានចូលរួមដេញថ្លៃទាំងអស់ដែលស្នើសុំ ។

មាត្រា ៣៧.-

សមាជិកទាំងអស់របស់អង្គភាពលទ្ធកម្ម "អល" គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា "គបវប" មន្ត្រីនាយកដ្ឋានលទ្ធកម្មសាធារណៈ អ្នកដេញថ្លៃ ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈដែលនឹងកំណត់ក្នុង អវបលស។ សមាជិករបស់អង្គភាពលទ្ធកម្ម មន្ត្រីនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសនេះ ជារៀងរាល់ឆ្នាំ។ អ្នកដេញថ្លៃ ត្រូវចុះហត្ថលេខារៀងរាល់ពេលដែលដាក់ពាក្យសុំដេញថ្លៃ ហើយ គបវប ក៏ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសនេះផងដែរ នៅរាល់ពេលយល់ព្រមលើរបាយការណ៍វាយតម្លៃ ។

## ជំពូក ៨

## ការប្តឹងតវ៉ា និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម

មាត្រា ៣៨.-

អ្នកដេញថ្លៃ ឬទីប្រឹក្សា មានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរនៅគ្រប់ដំណាក់កាលនៃដំណើរការធ្វើលទ្ធកម្ម។ ពាក្យប្តឹងតវ៉ានេះ ត្រូវដាក់ជូនសាមីស្ថាប័នអនុវត្តលទ្ធកម្មដោយបំពេញឈ្មោះ និងចុះហត្ថលេខាលើពាក្យប្តឹងតវ៉ា ហើយត្រូវចម្លងបណ្តឹងនេះ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើការពិនិត្យពាក្យប្តឹង និងផ្តល់ចម្លើយក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យប្តឹងតវ៉ា ។

ប្រសិនបើពាក្យប្តឹងតវ៉ាត្រូវបានធ្វើឡើង ក្នុងអំឡុងពេលវាយតម្លៃប្រគល់កិច្ចសន្យា សាមីស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបញ្ជាក់ថា បានទទួល និងលើកអង្គសេចក្តីនៃពាក្យប្តឹងតវ៉ានេះ ទៅពិចារណាក្នុងនីតិវិធីវាយតម្លៃ ។ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវឆ្លើយទៅនឹងការតវ៉ាភ្លាមៗ បន្ទាប់ពីការប្រគល់កិច្ចសន្យារួចហើយ ។ លិខិតឆ្លើយតបនេះត្រូវចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយច្បាប់ ។

## មាត្រា ៣៩.-

អ្នកដេញថ្លៃ ឬទីប្រឹក្សា ដែលមិនពេញចិត្តនឹងចម្លើយរបស់ស្ថាប័នអនុវត្តលទ្ធកម្ម មានសិទ្ធិប្តឹងបន្ថែមក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលស្ថាប័នអនុវត្តលទ្ធកម្មបានផ្តល់ចម្លើយ និងសុំឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ចម្លើយ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យប្តឹងតវ៉ា។

## មាត្រា ៤០.-

សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះបណ្តឹងតវ៉ា ជាសេចក្តីសំរេចចុងក្រោយ។ ប៉ុន្តែសេចក្តីសំរេចនេះ អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅតុលាការបាន ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃចេញសេចក្តីសម្រេច។

## មាត្រា ៤១.-

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការសាងសង់ និងទីប្រឹក្សា នៅក្រោមកិច្ចសន្យាហិរញ្ញប្បទានសាធារណៈ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈខ្ពស់បំផុត នៅក្នុងអំឡុងពេលជ្រើសរើស និងការអនុវត្តនីកិច្ចសន្យា ។

រាជរដ្ឋាភិបាលមានសិទ្ធិធ្វើអធិការកិច្ច និងពិនិត្យឡើងវិញ លើឯកសារដែលជាប់ពាក់ព័ន្ធនឹងការដេញថ្លៃ សំណើសុំដេញថ្លៃ និងកិច្ចសន្យារបស់អ្នកដេញថ្លៃ អ្នកទទួលការអ្នកផ្គត់ផ្គង់ និងទីប្រឹក្សា ទាំងអស់។

# ជំពូក ៩

# ទោសប្បញ្ញត្តិ

## មាត្រា ៤២.-

បុគ្គលទាំងអស់ដែលពាក់ព័ន្ធនឹងដំណើរការលទ្ធកម្ម ត្រូវរាយការណ៍ទៅគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា "គបវប" របស់ស្ថាប័នអនុវត្តលទ្ធកម្ម ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត នៅពេលដែលមានភស្តុតាងច្បាស់លាស់ដែលជាមូលដ្ឋាននាំឱ្យមានការសង្ស័យថា មាន អំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំ ។

នៅក្នុងន័យនៃអនុក្រឹត្យនេះ អំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំ ក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រូវបានកំណត់ដូចខាងក្រោម ៖

- " អំពើពុករលួយ " សំដៅដល់ ការសូក ឬការទទួលវត្ថុមានតម្លៃ ដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពមន្ត្រីសាធារណៈនៅក្នុងដំណើរការជ្រើសរើសប្រគល់កិច្ចសន្យា ឬនៅក្នុងការអនុវត្តន៍កិច្ចសន្យា ។

- " អំពើបន្លំ " សំដៅដល់ ការបកស្រាយបំភ្លៃហេតុការណ៍ ដើម្បីឱ្យមានឥទ្ធិពលលើដំណើរការជ្រើសរើសប្រគល់កិច្ចសន្យា ឬការអនុវត្តន៍កិច្ចសន្យា ធ្វើឱ្យខូចប្រយោជន៍របស់រាជរដ្ឋាភិបាល និងរួមជាមួយអំពើឃុបឃិតក្នុងចំណោមអ្នកដេញថ្លៃ ( មុន ឬក្រោយពេលដាក់សំណើសុំដេញថ្លៃ) ដើម្បីរៀបចំបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត បង្កើតកិរិតមិនមែនជាលក្ខណៈប្រកួតប្រជែង ធ្វើឱ្យខូចប្រយោជន៍របស់រាជរដ្ឋាភិបាល ក្នុងន័យមិនមែនជាលក្ខណៈប្រកួតប្រជែងដោយចំហ និងសេរី ។

- " អំពើឃុបឃិត " សំដៅដល់ ផែនការ ឬការរៀបចំរវាងអ្នកដេញថ្លៃពីរ ឬច្រើននាក់ ដែលរៀបចំឡើងដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត បង្កើតតម្លៃកិរិតមិនប្រកួតប្រជែង ឬដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយនៅក្នុងដំណើរការដេញថ្លៃ ឬជះឥទ្ធិពលលើការអនុវត្តន៍កិច្ចសន្យា ។

- " អំពើបង្ខិតបង្ខំ " សំដៅដល់ ការហាមឃាត់ ឬការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោល ធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិរបស់បុគ្គលនេះ ដើម្បីធ្វើឱ្យមានឥទ្ធិពលក្នុងការចូលរួមក្នុងដំណើរការលទ្ធកម្មរបស់បុគ្គលនេះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តន៍កិច្ចសន្យា ។

## មាត្រា ៤៣.-

នៅពេលស្ថាប័នអនុវត្តលទ្ធកម្មខកខានក្នុងការផ្តល់របាយការណ៍ស្តីពីសកម្មភាពលទ្ធកម្ម ដែលនឹងកំណត់ក្នុងអវបលស ឬលទ្ធផលនៃការត្រួតពិនិត្យលើពាក្យបណ្តឹងបង្ហាញថា ស្ថាប័នអនុវត្តលទ្ធកម្មមិនបានអនុវត្តត្រឹមត្រូវតាមវិធីសាស្ត្រ និងនីតិវិធីនៃលទ្ធកម្ម ឬមានភស្តុតាងបង្ហាញថា មានអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មនោះ ដាក់ជូនសេចក្តីព្រាងកិច្ចសន្យាទាំងអស់ ដោយមិនគិតពីកំរិតទឹកប្រាក់ ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការត្រួតពិនិត្យ និង សំរេចចុងក្រោយ ។

## មាត្រា ៤៤.-

នៅពេលដែលមន្ត្រីរាជការណាម្នាក់នៅក្នុងការអនុវត្តន៍កិច្ចលទ្ធកម្ម ត្រូវបានរកឃើញថា មានពាក់ព័ន្ធនឹងអំពើពុករលួយ អំពើកេងបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំ បុគ្គលនោះ អាចត្រូវទទួលទណ្ឌកម្មវិន័យផ្នែករដ្ឋបាល ។ ទណ្ឌកម្មវិន័យផ្នែករដ្ឋបាលនេះ មិនមែនជាឧបសគ្គដល់ដំណើរការនៃការចោទប្រកាន់ និងផ្តន្ទាទោសព្រហ្មទណ្ឌ ដោយយោងតាមច្បាប់ជាធរមានឡើយ ។

មាត្រា ៤៥.-

នៅពេលដែលអ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្គត់ផ្គង់ ក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជន ត្រូវបានរកឃើញថា មានពាក់ព័ន្ធក្នុងអំពើពុករលួយ អំពើកេងបន្លំ អំពើបង្ខិតបង្ខំ និងអំពើឃុបឃិតគ្នា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចសំរេចហាមឃាត់ក្រុមហ៊ុន ឬបុគ្គលទាំងនោះ មិនឱ្យចូលរួមក្នុងការផ្គត់ផ្គង់ ទំនិញ សំណង់ សេវាកម្ម ជាអចិន្ត្រៃយ៍ ឬក្នុងរយៈពេលមិនតិចជាងបីឆ្នាំ ។ ការហាមឃាត់នេះ មិនមែនជាឧបសគ្គ ដល់ដំណើរការនៃការចោទប្រកាន់ និងផ្តន្ទាទោសដោយយោងទៅតាមច្បាប់ជាធរមានឡើយ ។

## ជំពូក ១០

## អវសានប្បញ្ញត្តិ

មាត្រា ៤៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង-ស្ថាប័ន រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ប្រធានសហគ្រាសសាធារណៈ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៤៧
- កាលប្បវត្តិ-ឯកសារ